**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៩

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានគោលបំណង ៖

- ផ្តល់សមត្ថកិច្ចឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ធនធានដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព
- គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយនិរន្តរភាព និងសមធម៌
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ជួយឱ្យសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ សង្កាត់ ស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលធម្មជាតិនៃដី
- ឆ្លើយតបចំពោះសេចក្តីត្រូវការជីវភាពរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់
- ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាព និងមិនឱ្យប្រើប្រាស់ខុសទិសដៅ
- រួមចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់ ឱ្យបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសពីស្ថាប័ន អង្គភាពនានា និងពីផ្នែកឯកជន ដើម្បីបំពេញបន្ថែមចំពោះការរៀបចំកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

មាត្រា ៣ .-

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ព្រមទាំងដីឯកជនរបស់បុគ្គលឯកជនដែលស្ថិតនៅក្នុងឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤ .-

វាក្យសព្ទខាងក្រោមប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ÷

- **ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជនរបស់បុគ្គលឯកជន។
- **ផែនការអភិវឌ្ឍឃុំ សង្កាត់** សំដៅដល់ផែនការអភិវឌ្ឍនានាដែលបានអនុម័តជាផ្លូវការរួចហើយសម្រាប់ ឃុំ សង្កាត់ទាំងមូល ដើម្បីឱ្យឃុំ សង្កាត់នោះមានការរីកចម្រើនជាទូទៅ ជាពិសេសផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នោះបានល្អប្រសើរជាលំដាប់។
- **កម្មវិធីវិនិយោគនៅឃុំ សង្កាត់** សំដៅដល់កម្មវិធីវិនិយោគសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំ ដែលជាឧបករណ៍ចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចបាននូវចក្ខុវិស័យ ទិសដៅ និងយុទ្ធសាស្ត្រនានាដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់។
- **ផែនទីរដ្ឋបាលឃុំ សង្កាត់** សំដៅដល់ផែនទីរដ្ឋបាលដែលចេញផ្សាយដោយនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- **ផែនទីប្រើប្រាស់ដីឃុំសង្កាត់** សំដៅដល់ផែនទីដែលមានព័ត៌មានស្តីពីប្រភេទនៃការប្រើប្រាស់ដី តម្រុយដីព្រំប្រទល់ និងទីតាំងរដ្ឋបាលឃុំសង្កាត់ដែលមានកន្លងមក។

## ជំពូកទី២

## គោលការណ៍សម្រាប់រៀបចំផែនការ

មាត្រា ៥ .-

ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ÷

១. ត្រូវធ្វើតាមវិធីសាស្ត្រដែលមានលក្ខណៈចូលរួម ដោយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធពីគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់នីមួយៗ ព្រមទាំងពីក្រុមសង្គមស៊ីវិលដែលមានការពាក់ព័ន្ធនឹងការងារដីធ្លី។

២. ត្រូវស្របតាមគម្រោងផែនការអភិវឌ្ឍដែលមានជាផ្លូវការនៅថ្នាក់ឃុំ សង្កាត់ ដែលអាចជាប្រភេទនៃការអភិវឌ្ឍចម្រុះ ឬជាប្រភេទនៃការអភិវឌ្ឍផ្អែកតាមប្រភពធនធានជាក់លាក់នីមួយៗតាមទស្សនៈភូមិមួយផលិតផលមួយ ឬតាមលក្ខណៈពិសេសជាក់លាក់របស់តំបន់នីមួយៗ។

៣. ត្រូវយកផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់។

៤. ត្រូវតែបើកចំហរាល់ព័ត៌មានទាំងអស់ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

៥. ត្រូវផ្តល់អាទិភាពខ្ពស់ដល់តម្រូវការដីនៅមូលដ្ឋាន ឃុំ សង្កាត់សាមី នាពេលបច្ចុប្បន្ន និងទៅអនាគតសម្រាប់រយៈពេលពី ១០ (ដប់)ទៅ ១៥ (ដប់ប្រាំ) ឆ្នាំខាងមុខ សម្រាប់សេវា និងការប្រើប្រាស់ជាសាធារណៈសម្រាប់ការដោះស្រាយការតាំងទីលំនៅថ្មីដែលបណ្តាលមកពីគម្រោងអភិវឌ្ឍរបស់រដ្ឋ គម្រោងអភិវឌ្ឍរបស់មូលដ្ឋាន គ្រោះធម្មជាតិផ្សេងៗ ឬកំណើនប្រជាពលរដ្ឋ តាមរយៈការបម្រុងដីទុកសម្រាប់គោលដៅជាក់លាក់នីមួយៗស្របតាមបញ្ញត្តិច្បាប់ទាំងឡាយដូចជា ការផ្តល់ដីតាមរយៈសម្បទានដីសង្គមកិច្ចជាដើម។

៦. ធ្វើផែនការប្រើប្រាស់ដីមិនមែនជាការផ្តល់ដីឬបែងចែកដីជាក់ស្តែងនោះទេ។

## ជំពូកទី៣
## យន្តការ និងភារកិច្ច

**មាត្រា ៦ .-**

យន្តការសម្រាប់ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ មានដូចតទៅ ÷

១. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន ផ្តល់ព័ត៌មានជាក់លាក់នានា រៀបចំកិច្ចពិភាក្សា ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ជាមួយប្រជាជនក្នុងភូមិ ដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីជាលក្ខណៈផែនការលំអិតនិងជាម្ចាស់នៃផែនការប្រើប្រាស់ដីឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់តាំងជនបង្គោលមួយ ឬច្រើនរូបឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល និងធ្វើទំនាក់ទំនងជាប្រចាំជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ លើការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

២. ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពតាមការកំណត់ដោយមាត្រា ២៧ នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចសំខាន់ក្នុងការសម្របសម្រួលផ្តល់ការគាំទ្រផ្នែកបច្ចេកទេសចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងជួយកៀរគរការគាំទ្រពីភាគីពាក់ព័ន្ធនានា។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

ដើម្បីធ្វើការជាប្រចាំជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

៣. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តដែលមានសមាសភាពតាមការកំណត់ដោយមាត្រា ២៤ នៃអនុក្រឹត្យលេខ ១១៨ អនក្រ ប.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចពិនិត្យឡើងវិញ ផ្ដល់យោបល់កែសម្រួល សម្រេច និងត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

**មាត្រា ៧ .-**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានភារកិច្ចដូចតទៅ ÷

- ប្រមូល និងផ្ដល់ទិន្នន័យនៃការប្រើប្រាស់ដីជាក់ស្ដែងកន្លងមក
- ធ្វើការសិក្សា និងបង្ហាញអំពីសេចក្ដីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន និងពិចារណាអំពីការរៀបចំគម្រោងផែនការអភិវឌ្ឍឃុំ សង្កាត់ ព្រមទាំងកិច្ចសហការចាំបាច់ផ្សេងទៀតក្នុងដំណើរការរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ជូនដំណឹង និងបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត បានផ្ដល់យោបល់កែសម្រួលរួច
- ប្រមូល និងសង្ខេបមតិយោបល់សាធារណៈជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រោយការបិទផ្សាយជាសាធារណៈ
- លើកសំណើសុំកែប្រែផែនការទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ
- តាមដាន និងវាយតម្លៃការអនុវត្តផែនការ និងធ្វើរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ មេឃុំ ចៅសង្កាត់មានភារកិច្ចដឹកនាំកិច្ចប្រជុំនានាពាក់ព័ន្ធដល់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងទទួលខុសត្រូវលើការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ដែលបានអនុម័តរួចហើយ។

**មាត្រា ៨ .-**

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចតទៅ ÷

- ដឹកនាំការប្រជុំដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- រួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការវាយតម្លៃសេចក្ដីត្រូវការដី ស្ថានភាពជាក់ស្ដែងនៃដី និងសក្ដានុពល ដី ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ

- រួមសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ លើកសំណើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដោយមានសេចក្តីអធិប្បាយអំពីសេចក្តីត្រូវការដីរបស់មូលដ្ឋាន ស្ថានភាពជាក់ស្តែងនៃដីនិងសក្តានុពលដី និងគម្រោងរៀបចំផែនការអភិវឌ្ឍផ្សេងៗទៅអនាគតរបស់ឃុំ សង្កាត់
- ជួយធ្វើការកែតម្រូវគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ តាមការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត
- ជំរុញការអនុវត្តផែនការប្រើប្រាស់ដី ដែលបានសម្រេចជាផ្លូវការ និងជួយរៀបចំរបាយការណ៍បូកសរុបប្រចាំឆមាស និងឆ្នាំ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អំពីការអនុវត្តផែនការប្រើប្រាស់ដី ជាពិសេសដីដែលបានផ្តល់ ឬចែកឱ្យបុគ្គលឯកជន សមូហភាព ឬអង្គភាពរដ្ឋនានា នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងដីដែលនៅសល់ក្នុងផែនការមិនទាន់បានបែងចែក ព្រមទាំងដីដែលស្ថិតនៅក្រោមការគ្រប់គ្រងកាន់កាប់របស់អាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានក្នុងឃុំ សង្កាត់នោះ
- ដោះស្រាយទំនាស់ពាក់ព័ន្ធនឹងការប្រើប្រាស់ដីរវាងឃុំ សង្កាត់ និងឃុំ សង្កាត់
- ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។ សមាសភាពក្រុមនេះអាចមានពី ៣ (បី)ទៅ ៥ (ប្រាំ) នាក់ ដែលជាមន្ត្រីបច្ចេកទេសពីការិយាល័យជំនាញជុំវិញក្រុង ស្រុក ខណ្ឌ។

**មាត្រា ៩ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានភារកិច្ចដូចតទៅ ÷

- ដឹកនាំពិគ្រោះយោបល់សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ផ្តល់យោបល់ដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកែសម្រួលផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដោយពិចារណាជាមួយប្លង់មេ ផែនការអភិវឌ្ឍផ្សេងៗ និងការកំណត់តំបន់ប្រើប្រាស់ដីទាំងឡាយដែលបានសម្រេចជាផ្លូវការរួចហើយ
- សម្រេច និងត្រួតពិនិត្យលើការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ដែលសមាសភាពក្រុមនេះអាចមានពីបី (៣) ទៅប្រាំ (៥) នាក់ ជាមន្ត្រីបច្ចេកទេសពីមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ហើយមានភារកិច្ចសំខាន់ ជួយសម្របសម្រួលការងារអង្គភាពពាក់ព័ន្ធនៅជុំវិញរាជធានី ខេត្ត និងធ្វើជាគ្រូបណ្តុះបណ្តាលការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

- ប្រមូលសរុប និងលើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤
## នីតិវិធីនៃការរៀបចំផែនការ

**មាត្រា ១០ .-**

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម ÷

១. ក្រុមប្រឹក្សាឃុំ សង្កាត់ លើកសំណើសុំគោលការណ៍រៀបចំផែនការប្រើប្រាស់ដីទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណើសុំរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវធ្វើការសម្រេច និងឆ្លើយតបក្នុងរយៈពេលមិនលើសពី ២១ (ម្ភៃមួយ) ថ្ងៃ។

២. បន្ទាប់ពីមានការយល់ព្រមពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវរៀបចំសំណើថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណើថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃយ៉ាងយូរ ដើម្បីឱ្យគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត រៀបចំថវិកាស្របតាមបញ្ញត្តិដែលមានចែងក្នុងមាត្រា ១៩ នៃអនុក្រឹត្យនេះ។

៣. ក្រោយពីទទួលបានការឯកភាពថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមានការគាំទ្រពីដៃគូអភិវឌ្ឍ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងដោយមេឃុំ ចៅសង្កាត់ និងសមាជិកម្នាក់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលទទួលបន្ទុកការងារដី ត្រូវប្រជុំដើម្បីរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។ អង្គប្រជុំត្រូវចាត់តាំងក្រុមការងារសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងមានមេឃុំឬចៅសង្កាត់សាមី ចុះស្រង់ព័ត៌មានពី

ស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់ដីកន្លងមក ហើយគូសលើផែនទីរដ្ឋបាល និង/ឬ ផែនទីប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ប្រសិនបើមាន។

៤. ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ប្រជុំលើកទី ២ ដើម្បីពិចារណាអំពី :
   - ការរៀបចំផែនការប្រើប្រាស់ដី ដោយប្រើប្រាស់ផែនទីដែលមានទិន្នន័យ ឬព័ត៌មានពីស្ថានភាពប្រើប្រាស់ដីជាក់ស្តែងដែលមានកន្លងមក
   - ផែនការមេ ឬផែនការអភិវឌ្ឍឃុំ សង្កាត់ ឬផែនការអភិវឌ្ឍរបស់រដ្ឋផ្សេងទៀតដែលបានអនុម័តជាផ្លូវការរួចហើយ ឬមិនទាន់អនុម័ត ប្រសិនបើមាន
   - ការគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់នោះ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព
   - សេចក្តីត្រូវការដីរបស់ស្ថាប័ន អាជ្ញាធរផ្សេងៗ និងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឃុំ សង្កាត់។

៥. ពេលបានសម្រេចធ្វើផែនការនេះរួចហើយ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសេចក្តីព្រាងផែនការនេះទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីពិនិត្យ និងកែសម្រួល។

៦. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃ តាមទីកន្លែងជាក់ស្តែងនូវផែនការដែលបានពិនិត្យ និងកែសម្រួលរួចហើយដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមិនឯកភាពនឹងទិន្នន័យដែលបានបិទផ្សាយជាសាធារណៈមានសិទ្ធិតវ៉ាទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

៧. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រមូលសរុបមតិសាធារណៈ ពិនិត្យ និងលើកអនុសាសន៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យសម្រេចចុងក្រោយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។

៨. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ប្រជុំលើកទីពីរដើម្បីពិនិត្យមតិយោបល់សាធារណៈ និងអនុសាសន៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចចាត់បញ្ជូនក្រុមស៊ើបអង្កេតមួយទៅពិនិត្យ និងស្រង់យកព័ត៌មានបន្ថែមទៀតប្រសិនបើយល់ឃើញថាជាការចាំបាច់។ ក្រុមស៊ើបអង្កេតអាចប្រើពេលវេលាមិនឱ្យហួសពី ៣០ (សាមសិប) ថ្ងៃទេ។

៩. ការសម្រេចលើផែនការប្រើប្រាស់ដី ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃអង្គប្រជុំគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដែលមានសមាជិកចូលរួមប្រជុំយ៉ាងតិច ២/៣

(ពីរភាគបី) នៃសមាជិកទាំងអស់។ ក្រោយពីគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវបានសម្រេចរួចហើយ លេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវចម្លងឯកសារអំពីផែនការប្រើប្រាស់ដីនេះជូនគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឃុំ សង្កាត់សាមី។

១០. ប្រធានក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដី និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ជារៀងរាល់ឆមាស និងប្រចាំឆ្នាំ។

**មាត្រា ១១ ._**

ការរៀបចំ និងការអនុវត្តផែនការប្រើប្រាស់ដីលំអិតនៅក្នុងឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងផែនការ។

**មាត្រា ១២ ._**

ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើការផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យនេះឱ្យបានទូលំទូលាយដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលជាអ្នកអនុវត្តផ្ទាល់។

## ជំពូកទី៥
## ការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

**មាត្រា ១៣ ._**

ដើម្បីធានាប្រសិទ្ធភាពនៃផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវអនុវត្តតាមផែនការដែលបានសម្រេចជាផ្លូវការរួចហើយ តាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានជំនួយពីក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវដំណើរការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ដែលបានសម្រេចរួចហើយ ឱ្យមានប្រសិទ្ធភាព និងប្រកបដោយតម្លាភាព។

**មាត្រា ១៤ ._**

ដីដែលមានចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ មួយចំណែកអាចត្រូវបានផ្តល់ ឬបែងចែកឱ្យអង្គភាពរដ្ឋ ឬរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្របតាមផែនការប្រើប្រាស់ដីនោះ និងមួយចំណែក

ទៀតអាចផ្តល់ជាសម្បទានដីសង្គមកិច្ច ដោះស្រាយការតាំងទីលំនៅថ្មី ជាសម្បទានដីសេដ្ឋកិច្ច អាចលក់ ដូរ ជួល ឬអាចអនុញ្ញាតឱ្យប្រើប្រាស់រយៈពេលខ្លី ឬក៏សម្រាប់គម្រោងវិនិយោគផ្សេងៗរបស់រដ្ឋ និងរបស់មូលដ្ឋានដោយត្រូវគោរពតាមនីតិវិធីច្បាប់ជាធរមាន។

ចំណែកដីដែលមានចំណាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ ដីនោះត្រូវរក្សាទុកសម្រាប់បម្រើសេវាសាធារណៈ ឬសម្រាប់គ្រប់គ្រង និងប្រើប្រាស់ប្រកបដោយសមធម៌ និងនិរន្តរភាព។

**មាត្រា ១៥ ._**

ការអនុញ្ញាតឱ្យប្រើប្រាស់ដីរយៈពេលខ្លីគឺមិនលើសពី ០១ (មួយ) ឆ្នាំអាចបន្តជាថ្មីបានតែម្តងគត់ ហើយអាចដកហូតវិញបានគ្រប់ពេលវេលា។ ការអនុញ្ញាតនេះសម្រាប់ជូនប្រជាពលរដ្ឋក្រីក្រនៅមូលដ្ឋានឃុំ សង្កាត់ដែលត្រូវការដីចាំបាច់ ឬខ្វះដីសម្រាប់ធ្វើជម្រកស្នាក់នៅបណ្តោះអាសន្ន ឬធ្វើកសិកម្មចិញ្ចឹមជីវិតជាបណ្តោះអាសន្នក្នុងពេលរង់ចាំការបែងចែកដីក្នុងក្របខណ្ឌសម្បទានដីសង្គមកិច្ច ឬការតាំងទីលំនៅថ្មី។

ការអនុញ្ញាតនេះត្រូវមានការចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរច្បាស់លាស់ជាមួយមេឃុំ ចៅសង្កាត់។ ប្រជាពលរដ្ឋក្រីក្រដែលត្រូវការដី ឬខ្វះដី ត្រូវដាក់សំណើសុំការអនុញ្ញាតប្រើប្រាស់ដីរយៈពេលខ្លីជាបណ្តោះអាសន្នតាមរយៈមេភូមិទៅមេឃុំ ចៅសង្កាត់ ដោយមានបញ្ជាក់ទីតាំងដី និងគោលបំណងប្រើប្រាស់ដីជាក់លាក់។ កិច្ចសន្យាដែលមានកំណត់លក្ខខណ្ឌនៃការអនុញ្ញាតឱ្យប្រើប្រាស់ដីនោះ ត្រូវទុកជាឯកសារសាធារណៈនៅសាលាឃុំ សង្កាត់ និងត្រូវចម្លងជូនក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការអនុញ្ញាតឱ្យប្រើប្រាស់ដីរបស់រដ្ឋ ឬការការពារជនប្រើប្រាស់ដីរបស់រដ្ឋដោយគ្មានកិច្ចសន្យាជាលាយលក្ខណ៍អក្សរត្រឹមត្រូវ ឬដោយបំពានសិទ្ធិអំណាចរបស់អាជ្ញាធរ ត្រូវបានហាមឃាត់។

**មាត្រា ១៦ ._**

ការប្រើប្រាស់ដីដែលមិនស្របតាមផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវដកហូតយកមកវិញ ឬត្រូវបញ្ឈប់ការប្រើប្រាស់ចំពោះដីរដ្ឋ ឬត្រូវបញ្ឈប់ការប្រើប្រាស់ដីជាបណ្តោះអាសន្នចំពោះដីឯកជនរបស់បុគ្គលឯកជនក្នុងរយៈពេលពីរខែយ៉ាងយូរ។ ការដកហូត ឬការបញ្ឈប់ការប្រើប្រាស់ដី ត្រូវសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមសំណើរបស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ លើកលែងតែគម្រោងថ្នាក់ជាតិដែលត្រូវសម្រេចដកហូត ឬបញ្ឈប់ការប្រើប្រាស់ដីដោយថ្នាក់ជាតិ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ឱ្យបានជាប់ជាប្រចាំ។

រូបវន្តបុគ្គល ឬនីតិបុគ្គលមានសិទ្ធិប្តឹងតវ៉ាអំពីការសម្រេចបញ្ឈប់ការប្រើប្រាស់ដីឯកជនដែលសម្រេចដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ទៅស្ថាប័នមានសមត្ថកិច្ច ឬទៅតុលាការ។

មាត្រា ១៧ .-

ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវកត់ត្រានូវពីការកំណត់ និងការសម្រេចលើរបៀបប្រើប្រាស់ ឬការបែងចែកដីដែលបានធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច តាមនីតិវិធីជាធរមានចំពោះក្បាលដីនីមួយៗ របស់រដ្ឋ។

## ជំពូកទី៦
## ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

មាត្រា ១៨ .-

ក្រោយពីទទួលបានការឯកភាពពីក្រុមប្រឹក្សាឃុំសង្កាត់ និង/ឬក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ អាចស្នើទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដើម្បីកែប្រែផែនការប្រើប្រាស់ដីនៅក្នុង ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវសេចក្តីពន្យល់ពីមូលហេតុផ្សេងៗក្នុងការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តតាមនីតិវិធីដែលមានលក្ខណៈចូលរួម ដូច ដំណើរការធ្វើផែនការប្រើប្រាស់ដីពីដំបូងដែរ។

ក្នុងករណីចាំបាច់ដែលមានការតម្រូវពីរាជរដ្ឋាភិបាល ការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ មិនចាំបាច់គោរពតាមនីតិវិធីទូទៅឡើយ។ ការសម្រេចលើការកែប្រែផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់នេះ ត្រូវជូនដំណឹងដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងភាគីពាក់ព័ន្ធ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃជាមុន។

ក្រោយពីផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវបានកែប្រែរួចហើយ លេខាធិការដ្ឋាននៃគណៈកម្មាធិការ គ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវចម្លងឯកសារកែសម្រួលនេះជូនគ្រប់ស្ថាប័នពាក់ព័ន្ធ និងឃុំ សង្កាត់សាមី ដើម្បីអនុវត្ត។

## ជំពូកទី៧
## ថវិកាចំណាយសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

មាត្រា ១៩ .-

ថវិកាសម្រាប់ការងាររៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ បានមកពី :

- ថវិកាជាតិ ។
- ហិរញ្ញប្បទានបានមកពីក្នុងនិងក្រៅប្រទេស ឬពីដៃគូអភិវឌ្ឍ ។

នីតិវិធីនៃការស្នើសុំ និងប្រើប្រាស់ថវិកាសម្រាប់ធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**មាត្រា ២០ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានី និងអភិបាលខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា ២១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ